00979355

E301/5/5/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 21 / 03 / 2014
ម៉ោង (Time/Heure): 10:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Sann Rada

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

ចំពោះមុខ: ចៅក្រម **និល ណុន** ជាប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម **យ៉ា សុខន**
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម **យូរ ឧត្តរា**

កាលបរិច្ឆេទ: ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៤
ភាសាដើម: ខ្មែរ/អង់គ្លេស/បារាំង
ចំណាត់ថ្នាក់ឯកសារ: សាធារណៈ

# សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំពន្យារពេលការចាប់ផ្តើមសវនាការលើសំណុំរឿង ០០២/០២ រហូតដល់មានសាលក្រមស្ថាពរលើសំណុំរឿង ០០២/០១

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**ជនជាប់ចោទ**
នួន ជា
ខៀវ សំផន

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ពេជ អង្គ
Elisabeth SIMONNEAU FORT

**មេធាវីជនជាប់ចោទ**
សុន អរុណ
Victor KOPPE
គង់ សំអុន
Arthur VERCKEN
Anta GUISSÉ

## ១. សេចក្តីផ្តើម

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើពីមេធាវីការពារក្តីរបស់ ខៀវ សំផន សុំឱ្យពន្យារពេលការចាប់ផ្តើមសវនាការលើសំណុំរឿង ០០២/០២ រហូតដល់ពេលដែលអង្គជំនុំជម្រះតុលាការកំពូលបានសម្រេចជាស្ថាពរលើបណ្តឹងសាទុក្ខទាំងអស់ដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ និងជាពិសេស ទាក់ទងទៅនឹងការកំណត់ទម្រង់នៃការទទួលខុសត្រូវ និងវិសាលភាពជាក់លាក់នៃសំណុំរឿង ០០២/០១ ជាមុនសិន[1]។

## ២. សារណា

២. ជនជាប់ចោទ ខៀវ សំផន បានលើកឡើងថា ដោយពិចារណាអំពីការសម្រេចបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ និងការប្រកាសរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា សំណុំរឿង ០០២/០១ នឹងបង្កើតបានជា "មូលដ្ឋាន" សម្រាប់ការជំនុំជម្រះផ្សេងទៀតនៅពេលខាងមុខនោះ ដូច្នេះគោលការណ៍*អាជ្ញាអស់ជំនុំ* និងសុវត្ថិភាពគតិយុត្តិតម្រូវថា កិច្ចដំណើរការនីតិវិធីសម្រាប់ការជំនុំជម្រះនាពេលខាងមុខនោះមិនអាចចាប់ផ្តើមបានទេ ដរាបណាអង្គជំនុំជម្រះតុលាការកំពូលមិន

---

[1] *សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីរបស់ ខៀវ សំផន ស្តីពីភាពចាំបាច់នៃការរង់ចាំរហូតដល់ពេលមានសាលដីកាស្ថាពរក្នុងសំណុំរឿង ០០២/០១ មុននឹងចាប់ផ្តើមកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០២/០២* ឯកសារ E301/5/5 ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៤ "សំណើសុំ" កថាខណ្ឌ ៣១-៣៣ (បានអះអាងថា ត្រូវតែមានការបំភ្លឺថាតើជនជាប់ចោទមានការទទួលខុសត្រូវក្នុងឋានៈជាសមាជិកនៃសហឧក្រិដ្ឋកម្មរួម ដោយផ្អែកលើការអនុវត្តគោលនយោបាយទាំងប្រាំដែរឬទេ ដោយសារការទទួលខុសត្រូវនេះនឹងមានផលប៉ះពាល់ក្នុងសំណុំរឿងទីពីរ) កថាខណ្ឌ ៣៤, ៤០ (បានអះអាងថា សំអាងហេតុដែលបានបញ្ជាក់ក្នុងដីកាបំបែកកិច្ចដំណើរការនីតិវិធី ពោលគឺដើម្បីប្រើការជំនុំជម្រះដំណាក់ទីមួយជាមូលដ្ឋានសម្រាប់ការពិនិត្យលម្អិតថែមទៀតលើការចោទប្រកាន់ និងអង្គហេតុចោទប្រកាន់ដែលនៅសេសសល់ ប្រឆាំងនឹងជនជាប់ចោទនៅក្នុងការជំនុំជម្រះនាពេលខាងមុខ មិនអាចសម្រេចលទ្ធផលបានទេ ដរាបណាសំណុំរឿងទីមួយមិនទាន់ត្រូវបានវិនិច្ឆ័យជាស្ថាពរនៅឡើយ) កថាខណ្ឌ ៥៥-៥៩ (បានអះអាងថា បញ្ហាស្តីពីវិសាលភាពជាក់លាក់នៃសំណុំរឿង ០០២/០១ ស្ថិតក្នុងភាពមិនទាន់ច្បាស់នៅឡើយ និងអាចត្រូវបានដោះស្រាយតែតាមរយៈការប្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលភាគីអាចដាក់តែក្នុងនីតិវិធីប្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមតែប៉ុណ្ណោះ)។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៣ (កិច្ចប្រជុំរៀបចំសវនាការ) ទំព័រ ៩៨-៩៩, ១០៤, ១០៧ (ភាសាអង់គ្លេស)។ ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៣ (កិច្ចប្រជុំរៀបចំសវនាការ) ទំព័រ ៧១-៧២, ៨៥, ៩៧-៩៨ (ភាសាអង់គ្លេស)។ ប្រតិចារឹក ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤ (សវនាការតទល់) ទំព័រ ២៩-៣៣ (ភាសាអង់គ្លេស)។

ទាន់បានចេញសាលដីកាស្ថាពររបស់ខ្លួនលើបណ្តឹងសាទុក្ខដែលអាចមាននៅក្នុងសំណុំរឿង ០០២/០១ ទេនោះ។ ការដែលកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ មិនទាន់បានបញ្ចប់ ធ្វើឱ្យសំអាងហេតុនៅក្នុងសាលក្រមសំណុំរឿង ០០២/០១ របស់អង្គជំនុំជម្រះសាលាដំបូង មិនអាចបង្កើតបានជាមូលដ្ឋានសម្រាប់ការជំនុំជម្រះដំណាក់កាលផ្សេងទៀតនៃសំណុំរឿង ០០២ នាពេលខាងមុខបានទេ ពីព្រោះសំអាងហេតុទាំងនោះមិនអាចត្រូវបានចាត់ទុកថាជាការឆ្លុះបញ្ចាំងអំពីការពិតដែលមិនមានការតវ៉ា និងចងភ្ជាប់ភាគីដោយផ្អែកទៅតាមគោលការណ៍ *អាជ្ញាអស់ជំនុំ* បានឡើយ[2]។ ការចាប់ផ្តើមកិច្ចដំណើរការនីតិវិធីលើសំណុំរឿង ០០២/០២ មុនពេលមានសាលក្រម និងបណ្តឹងសាទុក្ខពាក់ព័ន្ធទាំងអស់ក្នុងសំណុំរឿង ០០២/០១ ត្រូវបានចប់ជាស្ថាពរ គឺជាការអនុវត្តផ្ទុយពីផលប្រយោជន៍នៃការសន្សំសំចៃផ្នែកធនធានតុលាការ។ ម្យ៉ាងវិញទៀត កិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២ នឹងត្រូវអនុវត្តដោយផ្អែកទៅលើការរកឃើញផ្នែកអង្គច្បាប់ ដែលអង្គជំនុំជម្រះតុលាការកំពូលអាចនឹងសម្រេចថា មានកំហុសឆ្គង[3]។ ក្នុងករណីបែបនេះ វាអាចនឹងប៉ះពាល់សិទ្ធិរបស់ជនជាប់ចោទ ខៀវ សំផន ក្នុងការអនុវត្តដោយមានប្រសិទ្ធភាពនូវសិទ្ធិប្តឹងសាទុក្ខរបស់គាត់ក្នុងសំណុំរឿង ០០២/០១ ហើយក៏ជាការរំលោភទៅលើសិទ្ធិរបស់គាត់ក្នុងការទទួលបាននូវពេលវេលាគ្រប់គ្រាន់ដើម្បីត្រៀមរៀបចំការការពារក្តីក្នុងសំណុំរឿង ០០២/០២ ផងដែរ[4]។

៣. ជាការឆ្លើយតប សហព្រះរាជអាជ្ញាបានលើកឡើងថា គោលការណ៍ *អាជ្ញាអស់ជំនុំ* មានអានុភាពអនុវត្តមានកម្រិត ហើយមិនអាចពន្លាតគោលការណ៍នេះរហូតដាក់ជាកាតព្វកិច្ចឱ្យអង្គជំនុំជម្រះសាលាដំបូងយកសំអាងហេតុរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងបណ្តឹងសាទុក្ខពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ ទៅអនុវត្តចំពោះសំណុំរឿង ០០២/០២ ឡើយ[5]។ ជាពិសេស ទោះបីជាក្រម

---

[2] សំណើសុំ កថាខណ្ឌ ២៦-៤១, ៥២-៥៤។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤ (កិច្ចប្រជុំរៀបចំសវនាការ) ទំព័រ ២៩-៣០, ៣៥ (ភាសាអង់គ្លេស)។

[3] សំណើសុំ កថាខណ្ឌ ៣៨-៣៩។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៣ (កិច្ចប្រជុំរៀបចំសវនាការ) ទំព័រ ៩៨-៩៩ (ភាសាអង់គ្លេស)។ ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៣ (កិច្ចប្រជុំរៀបចំសវនាការ) ទំព័រ ៦៨, ៧០ (ភាសាអង់គ្លេស)។

[4] សំណើសុំ កថាខណ្ឌ ៦១-៦២។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៣ (កិច្ចប្រជុំរៀបចំសវនាការ) ទំព័រ ១០៤ (ភាសាអង់គ្លេស)។

[5] ប្រតិចារឹក ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤ (សវនាការតទល់) ទំព័រ ១០-១១ (ភាសាអង់គ្លេស)។

នីតិវិធីព្រហ្មទណ្ឌកម្ពុជា បានចែងទទួលស្គាល់គោលការណ៍*អាជ្ញាអស់ជំនុំ* ក៏ដោយ ក៏ក្រមនីតិវិធីនេះមិនបានហាមឃាត់តុលាការជាន់ទាប ក្នុងការជំនុំជម្រះអង្គហេតុនៃសំណុំរឿងដែលជនជាប់ចោទដែលត្រូវបានជំនុំជម្រះនៅតុលាការជាន់ខ្ពស់ចំពោះបទល្មើសផ្សេង ប៉ុន្តែមានការពាក់ព័ន្ធនឹងបទល្មើសមុនឡើយ[6]។ លើសពីនេះទៅទៀត ជាការអនុវត្តនៅកំរិតអន្តរជាតិឃើញថាគោលការណ៍*អាជ្ញាអស់ជំនុំ* នេះមិនរារាំងការជំនុំជម្រះមួយផ្សេងទៀតចំពោះជនជាប់ចោទដែល ពាក់ព័ន្ធនឹងបទល្មើសផ្សេងទៀត ដោយគ្រាន់តែមានអង្គហេតុពាក់ព័ន្ធគ្នានោះទេ[7]។ ម្យ៉ាងវិញទៀត ប្រព័ន្ធច្បាប់ជាតិនានាដែលអនុញ្ញាតឱ្យបំបែកបទចោទពាក់ព័ន្ធទៅនឹងការចោទប្រកាន់ផ្សេងគ្នាប្រឆាំងនឹងជនជាប់ចោទដែល មិនតម្រូវឱ្យមានសាលក្រមស្ថាពរលើបណ្តឹងសាទុក្ខក្នុងកិច្ចដំណើរការនីតិវិធីដំណាក់កាលទីមួយ មុននឹងអាចបន្តការជំនុំជម្រះដំណាក់កាលបន្ទាប់នោះឡើយ[8]។

៤. ជាចុងក្រោយ សហព្រះរាជអាជ្ញាបានលើកឡើងថា អង្គជំនុំជម្រះគួរបដិសេធចោលសំណើសុំនេះដោយហេតុថាសំណើសុំនេះនឹងធ្វើឱ្យមានការពន្យារពេលដំណើរការនីតិវិធីយ៉ាងហោចណាស់មួយឆ្នាំកន្លះ ដែលនេះជាការបំពានលើការណែនាំរបស់អង្គជំនុំជម្រះតុលាការកំពូល ដែលបានបង្គាប់ឱ្យចាប់ផ្តើមកិច្ចដំណើរការនីតិវិធីលើសំណុំរឿង០០២/០២ ឱ្យបានឆាប់បំផុតតាមដែលអាចធ្វើបាន[9]។ ការសម្រេចចាប់ផ្តើមកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០២/០២ ឱ្យបានឆាប់តាមដែលអាចធ្វើទៅបានគឺជាការឆ្លើយតបប្រសើរបំផុតទៅលើផលប្រយោជន៍នៃការសន្សំសំចៃធនធានតុលាការ ដោយសារតែកិច្ចដំណើរការនេះនឹងប្រព្រឹត្តទៅក្នុងពេលជាមួយគ្នានឹងកិច្ចដំណើរការនីតិវិធីពាក់ព័ន្ធបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ដែរ[10]។

---

[6] ប្រតិចារឹក ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤ (សវនាការតទល់) ទំព័រ ១១ (ភាសាអង់គ្លេស)។

[7] ប្រតិចារឹក ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤ (សវនាការតទល់) ទំព័រ ១១-១២ (ភាសាអង់គ្លេស)។

[8] ប្រតិចារឹក ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤ (សវនាការតទល់) ទំព័រ ១៤ (ភាសាអង់គ្លេស)។

[9] ប្រតិចារឹក ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤ (សវនាការតទល់) ទំព័រ ៨-៩, ១៤-១៥ (ភាសាអង់គ្លេស)។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៣ (កិច្ចប្រជុំរៀបចំសវនាការ) ទំព័រ ៧៤-៧៥ (ភាសាអង់គ្លេស)។

[10] ប្រតិចារឹក ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤ (សវនាការតទល់) ទំព័រ ៩, ១៥ (ភាសាអង់គ្លេស)។ ដោយការរំពឹងថាការចេញសាលដីកាលើបណ្តឹងឧទ្ធរណ៍អាចនឹងកើតឡើងក្នុងពេលជាមួយគ្នានឹងការបញ្ចប់សវនាការសំណុំរឿង ០០២/០២ សហព្រះរាជអាជ្ញាបានលើកឡើងថា មេធាវីការពារក្តីនឹងមានឱកាសតវ៉ារាល់ការរកឃើញដែលខ្លួនជំទាស់ នៅក្នុងសំណុំរឿង ០០២/០១ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២ នៅពេលបញ្ចប់សវនាការដេញដោលរឿងក្តីនេះ៖ ប្រតិចារឹក ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤ (សវនាការតទល់) ទំព័រ ១៣ (ភាសាអង់គ្លេស)។

៥. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងថា សំណើសុំរបស់មេធាវីការពារក្តីលោក ខៀវ សំផន គ្មានមូលដ្ឋានផ្លូវច្បាប់ទេ ដោយសារវិធានផ្ទៃក្នុង និងគោលការណ៍ *អាជ្ញាអស់ជំនុំ* មិនតម្រូវឱ្យអង្គជំនុំជម្រះសាលាដំបូងពន្យារពេលការចាប់ផ្តើមនីតិវិធីលើសំណុំរឿង ០០២/០២ ក្នុងពេលរង់ចាំសាលក្រមស្ថាពរក្នុងសំណុំរឿង ០០២/០១ ឡើយ។ លើសពីនេះទៀត ការពន្យារដំណើរការនីតិវិធីនឹងមិនឆ្លើយតបទៅនឹងផលប្រយោជន៍នៃការសន្សំសំចៃធនធានតុលាការ ឬផលប្រយោជន៍របស់ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណីឡើយ[11]។

៦. មេធាវីការពារក្តីលោក នួន ជា បានលើកឡើងនូវការព្រួយបារម្ភអំពីបញ្ហាសុខភាពរបស់ជនជាប់-ចោទ និងបានបង្ហាញថាលោក នួន ជា មានបំណងចាប់ផ្តើមសវនាការសំណុំរឿង ០០២/០២ ក្នុងពេលឆាប់បំផុត ហើយគាត់បានជំទាស់ទៅនឹងសំណើសុំពន្យារពេលនេះ[12]។

## ៣. <u>សំអាងហេតុ</u>

### ៣.១. <u>អាជ្ញាអស់ជំនុំ និងសុចរិតភាពគតិយុត្តិ</u>

៧. ជនជាប់ចោទ ខៀវ សំផន បានលើកឡើងថា គោលការណ៍*អាជ្ញាអស់ជំនុំ* នៅក្នុងករណីនេះពាក់ព័ន្ធទៅនឹងការពិចារណាថាតើអង្គជំនុំជម្រះសាលាដំបូងអាចចាប់ផ្តើមដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២ បានដែរ ឬទេ មុនពេលដែលបណ្តឹងសាទុក្ខពាក់ព័ន្ធនឹងសំណុំរឿង០០២/០១ មិនទាន់ត្រូវបានបញ្ចប់ជាស្ថាពរ។ ការលើកឡើងបែបនេះ គឺជាការលើកឡើងដោយមិនសមស្រប។

៨. កន្លងមក អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានសម្រេចថា គោលការណ៍*អាជ្ញាអស់ជំនុំ* អនុវត្តចំពោះតែក្នុងករណីដែលសំណុំរឿងមួយបានឈានដល់សេចក្តីសម្រេចស្ថាពរពាក់ព័ន្ធនឹងភាគីនិងអង្គហេតុដូចគ្នាប៉ុណ្ណោះ[13]។ អនុលោមតាមក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក សាលក្រមលើអង្គសេចក្តីមិន

---

[11] ប្រតិចារឹក ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤ (សវនាការតទល់) ទំព័រ ១៧-១៩ (ភាសាអង់គ្លេស)។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៣ (កិច្ចប្រជុំរៀបចំសវនាការ) ទំព័រ ៧៧-៧៨ (ភាសាអង់គ្លេស)។

[12] ប្រតិចារឹក ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤ (សវនាការតទល់) ទំព័រ ២១-២៣ (ភាសាអង់គ្លេស)។

[13] អង្គជំនុំជម្រះសាលាដំបូង សេចក្តីសម្រេចលើអញ្ញត្រកម្មរបស់ អៀង សារី តាមវិធាន ៨៩ (*Ne bis in idem* *"គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ" និងការលើកលែងទោស និងការអនុគ្រោះទោស)* ឯកសារ E51/15 ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១១ កថាខណ្ឌ ២៧។ ក្រមនីតិវិធីព្រហ្មទណ្ឌបានទទួលស្គាល់គោលការណ៍ *អាជ្ញាអស់ជំនុំ* មាត្រា ១២ នៃ សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំពន្យារពេលការចាប់ផ្តើមសវនាការលើសំណុំរឿង ០០២/០២ រហូតដល់មានសាលក្រមស្ថាពរលើសំណុំរឿង ០០២/០១ ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៤/សាធារណៈ

ទាន់ចូលជាស្ថាពរទេ រហូតទាល់តែនីតិវិធីបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមនេះ ត្រូវបានបញ្ចប់សព្វគ្រប់[14]។ ហេតុដូច្នេះ មុនពេលដែលសាលក្រមនៃសំណុំរឿង ០០២/០១ ចូលជាស្ថាពរនោះ គោលការណ៍អាជ្ញាអស់ជំនុំមិនយកមកអនុវត្តនោះទេ ។ នេះមានន័យថា គោលការណ៍អាជ្ញាអស់ជំនុំមិនអាចយកមកធ្វើជាមូលដ្ឋាន នៃការពន្យារពេលការចាប់ផ្ដើមកិច្ចដំណើការនីតិវិធីលើសំណុំរឿង ០០២/០២ រហូតទាល់តែសំណុំរឿង ០០២/០១ ត្រូវបានសម្រេចស្ថាពរនោះទេ ។ ការដែលលើកឡើងថា ផលប្រយោជន៍នៃការសន្សំសំចៃផ្នែកធនធានតុលាការអាចនឹងមានលក្ខណៈល្អប្រសើ ប្រសិនបើតុលាការរង់ចាំរហូតទាល់តែសាលក្រមនៃសំណុំរឿង ០០២/០១ ចូលជាស្ថាពរនោះ គឺមិនអាចយកមកធ្វើជាមូលដ្ឋានដើម្បីភ្ជាប់ទៅនឹងការអនុវត្តគោលការណ៍អាជ្ញាអស់ជំនុំបាននោះទេ ហើយដែលចំណុចនេះនឹងមានពន្យល់ខាងក្រោម ។

៩. ជនជាប់ចោទ ខៀវ សំផន បានលើកឡើងផងដែរថា គោលការណ៍សុវត្ថិភាពគតិយុត្តិតម្រូវថា អង្គជំនុំជម្រះសាលាដំបូងត្រូវរង់ចាំការបញ្ចប់កិច្ចដំណើរការនីតិវិធីលើបណ្ដឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ជាមុនសិន មុននឹងអាចចាប់ផ្ដើមសំណុំរឿង ០០២/០២ បាន។ ប៉ុន្តែ ទឡ្ហីករណ៍ដែលបានលើកឡើងដើម្បីគាំទ្រទៅនឹងអំណះអំណាងនេះ គឺមានភាពមិនច្បាស់លាស់នោះទេ។ ម្យ៉ាងទៀត ទឡ្ហីករណ៍ទាំងនោះគ្រាន់តែចង់បង្ហាញអំពីភាពមិនច្បាស់លាស់អំពីវិសាលភាពនៃសំណុំរឿង ០០២/០១ ដោយសារតែបញ្ញាត្តិភាពនៃសាលដីកាស្ថាពររបស់អង្គជំនុំជម្រះតុលាការកំពូល លើបណ្ដឹងសាទុក្ខ លើបញ្ហាមួយចំនួនប៉ុណ្ណោះ ដូចជា ការកំណត់របស់អង្គជំនុំជម្រះសាលា

---

ក្រមនេះចែងថា "ដោយអនុវត្តតាមគោលការណ៍អាជ្ញាអស់ជំនុំ ជនណាដែលត្រូវបានតុលាការសម្រេចឲ្យរួចខ្លួនជាស្ថាពរហើយ ជននោះមិនអាចត្រូវបានចោទប្រកាន់ទៀតទេចំពោះអំពើដែល ទោះបីជាក្រោមការកំណត់បទល្មើសថ្មីផ្សេងក៏ដោយ"។ *សូមមើលផងដែរ* រឿងក្ដីរដ្ឋអាជ្ញា ទល់នឹង *Delalić និងជនដទៃទៀត* (*"Celebici"*) *អង្គជំនុំជម្រះសាលាដំបូងនៃ*តុលាការ ICTY លេខ IT-96-21-T *សាលក្រម* ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ កថាខណ្ឌ ២២៨ ("គោលការណ៍ *អាជ្ញាអស់ជំនុំ* អនុវត្តតែ *ក្នុងចំណោមភាគី (inter partes)* ក្នុងរឿងក្ដីមួយ កាលណាបញ្ហាត្រូវបានសម្រេចរួចហើយតាមផ្លូវតុលាការនៅក្នុងរង្វង់រឿងក្ដីនោះ។ ... ក្នុងរឿងក្ដីព្រហ្មទណ្ឌ អានុភាពទ្រឹស្ដី*អាជ្ញាអស់ជំនុំ* នៅកម្រិតត្រឹមតែសំនួរថាតើបញ្ហាជាក់លាក់ ត្រូវបានដោះស្រាយសព្វគ្រប់អស់ហើយឬនៅ កាលណាតុលាការត្រូវជំនុំជម្រះលើកទីពីរលើបុគ្គលដដែល បន្ទាប់ពីបុគ្គលនោះត្រូវបានជំនុំជម្រះពីមុនម្ដងហើយ"។

[14] អង្គជំនុំជម្រះតុលាការកំពូល សេចក្ដីសម្រេចលើបណ្ដឹងសារទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីវិសាលភាពសំណុំរឿងលេខ ០០២/០១ ឯកសារ E163/5/1/13 ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ កថាខណ្ឌ ២៥ ។

ដំបូងអំពីគោលនយោបាយរបស់បក្សកុម្មុយនីសកម្ពុជា និងទម្រង់នៃការទទួលខុសត្រូវដែលអាចនឹងត្រូវយកមកអនុវត្តចំពោះជនជាប់ចោទក្នុងសំណុំរឿង ០០២/០១ ហើយបញ្ហាមួយទៀតគឺអំពីលទ្ធភាពនៃការប្ដឹងសារទុក្ខទៅលើរាល់សេចក្ដីសម្រេចដែលទាក់ទងទៅនឹងការទទួលយក និងការបង្ហាញនូវភស្តុតាង[15] ។ ចំពោះបញ្ហាទាក់ទងនឹងការសន្សំសំចៃផ្នែកធនធានតុលាការ ដែលជនជាប់ចោទ ខៀវ សំផន លើកឡើងនោះ គឺត្រូវបានដោះស្រាយ នៅផ្នែកខាងក្រោម ។ ដោយថ្លឹងថ្លែងអំពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងឆាប់រហ័សរបស់ជនជាប់ចោទ អង្គជំនុំជម្រះយល់ថា បញ្ហាដែលបានលើកឡើងទាំងនេះ គឺមិនមានមូលដ្ឋានគតិយុត្តិត្រឹមត្រូវក្នុងការពន្យារពេលការចាប់ផ្ដើមសំណុំរឿង ០០២/០២ នោះទេ ។ ដូច្នេះ អង្គជំនុំជម្រះសម្រេចបដិសេធសំណើសុំនេះ។

### ៣.២. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងឆាប់រហ័ស

១០. តាមមាត្រា ៣៣ ថ្មីនៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក អង្គជំនុំជម្រះត្រូវធានាថា ការជំនុំជម្រះត្រូវប្រព្រឹត្តទៅឱ្យបានត្រឹមត្រូវ និងឆាប់រហ័ស ទៅតាមនីតិវិធីជាធរមាន។ ដើម្បីសម្រេចទិសដៅនេះ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ច្រើនលើកច្រើនសាអំពីសារៈសំខាន់ នៃការបន្តកិច្ចដំណើរការសវនាការលើសំណុំរឿង ០០២/០២ ឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន។ ជាពិសេស នៅថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣ អង្គជំនុំជម្រះតុលាការកំពូលបានបង្គាប់ថា អង្គជំនុំជម្រះសាលាដំបូងត្រូវតែចាប់ផ្ដើមសវនាការដេញដោលលើភស្តុតាងក្នុងសំណុំរឿង ០០២/០២ ឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន បន្ទាប់ពីការធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលលើសំណុំរឿង ០០២/០១[16]។ នៅថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៣ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ម្ដងទៀតពីភាពចាំបាច់នៃការចាប់ផ្ដើមសវនាការឱ្យបានឆាប់រហ័សលើសំណុំរឿង

[15] សំណើសុំ កថាខណ្ឌ ៣១-៣៣, ៥៥-៦០។ ប្រតិចារឹក ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤ (សវនាការតទល់) ទំព័រ ៣០-៣១, ៣៣, ៣៨-៣៩ (ភាសាអង់គ្លេស)។

[16] អង្គជំនុំជម្រះតុលាការកំពូល សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្ដីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២៖ សេចក្ដីសង្ខេបនៃសំអាងហេតុ ឯកសារ E284/4/7 ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣ កថាខណ្ឌ ១១, ១៣។ *សូមមើលផងដែរ* អង្គជំនុំជម្រះតុលាការកំពូល សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្ដីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ ឯកសារ E284/4/8 ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣ កថាខណ្ឌ ៧២។

00979362



០០២/០២ ដោយបានសង្កត់ធ្ងន់ថា អង្គជំនុំជម្រះតុលាការកំពូលរំពឹងចង់បានលទ្ធផលជាក់ស្តែង និងបានលើកឡើងម្តងទៀត អំពីសេចក្តីបង្គាប់របស់ខ្លួនមុនៗ ដែលថា អង្គជំនុំជម្រះសាលាដំបូង ត្រូវតែចាប់ផ្តើមសវនាការជេញដោលលើភស្តុតាងលើសំណុំរឿង ០០២/០២ ឱ្យបានឆាប់បំផុត តាមដែលអាចធ្វើទៅបាន បន្ទាប់ពីការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាជេញដោលសំណុំរឿង ០០២/០១[17]។ នៅថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ឡើងវិញអំពីកាតព្វកិច្ចរបស់ អ.វ.ត.ក ក្នុងការបញ្ចប់កិច្ចដំណើរការនីតិវិធីជំនុំជម្រះ ទៅលើបទចោទទាំងអស់ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជម្រះក្នុងពេលវេលាមួយសមស្រប ដោយបានបញ្ជាក់ថា "អ.វ.ត.ក ចាំបាច់ត្រូវប្រើប្រាស់ថ្ងៃធ្វើការដែលមានឱ្យបានហ្មត់ចត់ ដើម្បីជានាសម្រេចឱ្យអស់នូវបទចោទទាំងឡាយដែលសេសសល់ ឱ្យបានឆាប់ដែលអាចធ្វើទៅបាន"[18] និងបានលើកយោងទៅ "ភាពចាំបាច់ជាបន្ទាន់ សម្រាប់ដោះស្រាយលើបទចោទដែលនៅសេសសល់ក្នុងសំណុំរឿង ០០២"[19]។ ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន បានច្រានចោលការបង្គាប់ខាងលើ ដោយ

---

[17] អង្គជំនុំជម្រះតុលាការកំពូល សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលា-ដំបូង ទៅលើសំណើសុំដោះលែង ខៀវ សំផន ឱ្យនៅក្រៅឃុំជាបន្ទាន់ ឯកសារ E275/2/3 ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៣ កថាខណ្ឌ ៣៧, ៥១។

[18] អង្គជំនុំជម្រះតុលាការកំពូល សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ ឯកសារ E284/4/8 ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣ កថាខណ្ឌ ៧២។ *សូមមើលផងដែរ* អង្គជំនុំជម្រះតុលាការកំពូល សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីវិសាលភាពនៃសំណុំរឿងលេខ ០០២/០១ ឯកសារ E163/5/1/13 ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ កថាខណ្ឌ ៥១។

[19] អង្គជំនុំជម្រះតុលាការកំពូល សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ ឯកសារ E284/4/8 ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣ កថាខណ្ឌ ៧៤។ ទោះបីជា អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់អានុសាសន៍ឱ្យបង្កើតក្រុមប្រឹក្សាជំនុំជម្រះទីពីរ ដើម្បីបន្តដំណើរការនីតិវិធីសំណុំរឿង ០០២/០២ ក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថាការបង្កើតក្រុមប្រឹក្សានេះនឹងមិនដំណើរការឆាប់រហ័សជាងក្រុមប្រឹក្សាបច្ចុប្បន្ន ហើយក៏មិនឆ្លើយតបទៅនឹងផលប្រយោជន៍នៃយុត្តិធម៌នោះទេ៖ អនុស្សរណៈរបស់ប្រធានអង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងការតែងតាំងក្រុមប្រឹក្សាជំនុំជម្រះទីពីរនៅក្នុងអង្គជំនុំជម្រះសាលាដំបូង ដើម្បីជំនុំជម្រះលើការចោទប្រកាន់ដែលមិនទាន់ត្រូវបានជំនុំជម្រះនៅក្នុងសំណុំរឿង ០០២ ឯកសារ E301/4 ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១៣។

អះអាងថា ការបង្គាប់នេះមានភាពអយុត្តិធម៌ខ្លាំងណាស់ចំពោះជនជាប់ចោទ ហើយអង្គជំនុំជម្រះតុលាការកំពូលពិតជាគ្មានចេតនាធ្វើបែបនេះនោះទេ[20]។

១១. ដោយពិចារណាអំពីរយៈពេលនៃកិច្ចដំណើរការនីតិវិធីលើបណ្ដឹងសាទុក្ខក្នុងសំណុំរឿង ០០១ ដែលមានជនជាប់ចោទតែម្នាក់នោះ សហព្រះរាជអាជ្ញាបានប៉ាន់ប្រមាណថា ការពន្យារពេលក្នុងសំណុំរឿង ០០២ តាមការស្នើនោះ អាចនឹងអូសបន្លាយពេលយ៉ាងហោចណាស់មួយឆ្នាំកន្លះ[21]។ រយៈពេលនេះច្រើនជាងទ្វេរដងពីរយៈពេល ដែលអង្គជំនុំជម្រះសាលាដំបូងបានគ្រោងទុកសម្រាប់សរសេរសាលក្រមសំណុំរឿង ០០២/០១ ហើយអង្គជំនុំជម្រះតុលាការកំពូលក៏បានបញ្ជាក់រួចហើយពីហានិភ័យនៃការរំលោភទៅលើសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយឆាប់រហ័ស[22]។ ទោះបីជាអង្គជំនុំជម្រះពិនិត្យឃើញថា ខៀវ សំផន បានត្រៀមខ្លួនរួចជាស្រេចក្នុងការលះបង់នូវសិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះដោយឆាប់រហ័សក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូង ត្រូវធានានូវតុល្យភាពនៃផលប្រយោជន៍របស់ភាគីទាំងអស់ក្នុងរឿងក្ដីចំពោះមុខខ្លួន[23]។

១២. ដូចបានលើកឡើងខាងលើ មេធាវីការពារក្ដីលោក ខៀវ សំផន បានអះអាងថា ការរំលោភលើសិទ្ធិរបស់ជនជាប់ចោទអាចកើតមានឡើង ដោយសារខ្លួនមិនបានដឹងអំពី ថាតើអង្គជំនុំជម្រះនឹងត្រូវដោះស្រាយយ៉ាងដូចម្ដេចទៅលើលក្ខខណ្ឌទូទៅ ដែលតម្រូវឱ្យមានចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ, ការចោទប្រកាន់ដោយផ្អែកទៅលើទ្រឹស្ដីសហឧក្រិដ្ឋកម្មរួម និងការកំណត់អំពីវិសាលភាពនៃសំណុំរឿង ០០២/០១[24]។ ដូចដែលសហព្រះរាជអាជ្ញាបានបញ្ជាក់ខាងលើ មេធាវីការពារក្ដី

---

[20] ប្រតិចារឹក ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤ (សវនាការតទល់) ទំព័រ ៣៧-៣៩ (ភាសាអង់គ្លេស)។

[21] ប្រតិចារឹក ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤ (សវនាការតទល់) ទំព័រ ៨-៩, ១៤ (អាចនឹងរហូតដល់ ២ ឆ្នាំ) (ភាសាអង់គ្លេស)។

[22] អង្គជំនុំជម្រះតុលាការកំពូល សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្ដីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ ឯកសារ E284/4/8 ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣ កថាខណ្ឌ ៤៦, ៧៤។

[23] រឿងក្ដីរដ្ឋអាជ្ញា ទល់នឹង *Kvočka និងជនដទៃទៀត អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ* ICTY *លេខ* IT-98-30/1-AR73.5 សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខបន្ទាន់បង្ខំរបស់ជនជាប់ចោទ *Zoran Zigic* ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទី ១ ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០០, ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០១ កថាខណ្ឌ ២០-២១។

[24] សំណើសុំ កថាខណ្ឌ ៣១-៣៣, ៥៧។

លោក ខៀវ សំផន មិនបានបញ្ជាក់ពីផលប៉ះពាល់ជាក់លាក់ ដែលខ្លួនអះអាងថា ជនជាប់ចោទនឹងត្រូវទទួលរងពីកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២ ក្នុងពេលដែលមិនទាន់មានសាលដីកាស្ថាពររបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០១ នោះ។ ក្នុងករណីនេះ អង្គជំនុំជម្រះសាលាដំបូងយល់ស្របជាមួយនឹងសហព្រះរាជអាជ្ញាថា គ្មានផលប៉ះពាល់ជាក់លាក់ណាមួយទៅលើជនជាប់ចោទនោះទេ ព្រោះភាគីទាំងអស់នៃសំណុំរឿង ០០២/០២ គឺស្ថិតក្នុងស្ថានភាពដូចគ្នា[25]។

១៣. មេធាវីការពារក្តីលោក ខៀវ សំផន បានអះអាងថា សិទ្ធិរបស់ខ្លួនក្នុងការត្រៀមរៀបចំបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ឬ សិទ្ធិក្នុងការត្រៀមរៀបចំការពារក្តីប្រកបដោយប្រសិទ្ធភាពក្នុងសំណុំរឿង ០០២/០២ នឹងត្រូវរំលោភ ដោយសារខ្លួនត្រូវត្រៀមរៀបចំបំពេញកិច្ចការទាំងពីរក្នុងពេលតែមួយជាមួយគ្នា។ ចំពោះបញ្ហានេះ អង្គជំនុំជម្រះសូមបញ្ជាក់ម្តងទៀតថា គ្រប់ភាគីទាំងអស់គឺស្ថិតក្នុងស្ថានភាពដូចគ្នា។ អង្គជំនុំជម្រះសាលាដំបូងក៏សូមរំលឹកផងដែរថា ភាគីទាំងអស់មានលទ្ធភាពពិនិត្យមើលសំណុំរឿង ០០២ ចាប់តាំងពីដំណាក់កាលស៊ើបអង្កេត និងបានបន្តការងាររបស់ខ្លួនរហូតមកដល់ដំណាក់កាលជំនុំជម្រះ ដោយផ្អែកលើមូលដ្ឋាននៃសំណុំរឿងទាំងមូល។ ហេតុដូច្នេះ ភាគីទាំអស់មិនអាចអះអាងថាខ្លួនគ្មានពេលវេលាគ្រប់គ្រាន់ដើម្បីត្រៀមរៀបចំសម្រាប់កិច្ចដំណើរការនីតិវិធីនាពេលអនាគតបានឡើយ។

១៤. លើសពីនេះទៅទៀត ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន បានលើកឡើងថា ប្រសិនបើសំណុំរឿង ០០២/០២ ចាប់ផ្តើមក្រោយពេលដែលសំណុំរឿង ០០២/០១ ត្រូវបានសម្រេចស្ថាពរ ហើយមិនត្រូវបានកែប្រែដោយសារតែបណ្តឹងសាទុក្ខនោះ ដូច្នេះ ការសន្សំសំចៃធនធានតុលាការគឺអាចធ្វើបានច្រើន ។ ផ្ទុយពីអ្វីដែលបានលើកឡើងនេះ អង្គជំនុំជម្រះសាលាដំបូង យល់ឃើញថា ការចាប់ផ្តើមកិច្ចដំណើរការនីតិវិធីលើសំណុំរឿង ០០២/០២ មុនពេលមានសាលដីកាលើបណ្តឹងសាទុក្ខដែលអាចមានក្នុងសំណុំរឿង ០០២/០១ នោះ នឹងការពារនូវផលប្រយោជន៍របស់ជនជាប់ចោទទាំងពីរ ជាពិសេសគឺសិទ្ធិរបស់ពួកគាត់ក្នុងការទទួលបានការជំនុំជម្រះដោយឆាប់រហ័ស និងសិទ្ធិទទួលបានការសម្រេចជាស្ថាពរឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន។ វាជាការប៉ាន់ប្រមាណមួយសមស្របដែលថា អង្គជំនុំជម្រះតុលាការកំពូលនឹងចេញសាលដីកាលើសំណុំរឿង

---

[25] ប្រតិចារឹក ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤ (សវនាការតទល់) ទំព័រ ១៣ (ភាសាអង់គ្លេស)។ សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំពន្យារពេលការចាប់ផ្តើមសវនាការលើសំណុំរឿង ០០២/០២ រហូតដល់មានសាលក្រមស្ថាពរលើសំណុំរឿង ០០២/០១ ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៤/សាធារណៈ:

០០២/០១ មុនពេលការជំនុំជម្រះលើសំណុំរឿង ០០២/០២ ត្រូវបានបញ្ចប់ ។ ភាគីនានានឹងមានឱកាសធ្វើសេចក្តីសន្និដ្ឋាននាពេលនោះ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងរាល់បញ្ហាដែលអង្គជំនុំជម្រះតុលាការកំពូលបានសម្រេច ហើយដែលមានការទាក់ទងទៅនឹងសំណុំរឿង ០០២/០២។ លើសពីនេះទៀត ភាគីទាំងអស់នឹងនៅតែមានសិទ្ធិដាក់បណ្តឹងសាទុក្ខ ទៅអង្គជំនុំជម្រះតុលាការកំពូល ដោយអនុលោមទៅតាមវិធាន ១០៤ នៃផ្ទៃក្នុង។

១៥. អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការចាប់ផ្តើមកិច្ចដំណើរការនីតិវិធីលើសំណុំរឿង ០០២/០២ នឹងធានាផងដែរនូវផលប្រយោជន៍ជាមូលដ្ឋានរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះក្នុងការទទួលបានយុត្តិធម៌ប្រកបដោយអត្ថន័យ និងទាន់ពេលវេលា ។

១៦. ហេតុដូច្នេះ មេធាវីការពារក្តីលោក ខៀវ សំផន មិនបានផ្តល់មូលហេតុសមស្រប ដែលតម្រូវឱ្យអង្គជំនុំជម្រះសាលាដំបូងត្រូវពន្យារពេលការចាប់ផ្តើមកិច្ចដំណើរការនីតិវិធីលើសំណុំរឿង ០០២/០២ រហូតដល់ពេលដែលអង្គជំនុំជម្រះតុលាការកំពូលបានសម្រេចជាស្ថាពរលើបណ្តឹងសាទុក្ខទាំងអស់ដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ នោះទេ។

**តាមសំអាងហេតុដូចបានរៀបរាប់ខាងលើ អង្គជំនុំជម្រះសាលាដំបូងសម្រេចៈ**

**បដិសេធ** សំណើសុំរបស់ ខៀវ សំផន សុំឱ្យពន្យារពេលការចាប់ផ្តើមសវនាការ លើសំណុំរឿង ០០២/០២ រហូតដល់ពេលដែលអង្គជំនុំជម្រះតុលាការកំពូលបានសម្រេចជាស្ថាពរ លើបណ្តឹងសាទុក្ខទាំងអស់ដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៤

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E.C.C.C. C.E.T.C.

**និល ណុន**